# សេចក្តីជូនដំណឹង

## <u>លិខិតអញ្ជើញចូលរួម</u>

## ពិធីប្រគល់វិញ្ញាបនបត្រដល់បេក្ខជនផ្តាច់ព្រ័ត្រនៃយុទ្ធនាការ «ខ្ញុំមានតំលៃ»

**កាលបរិច្ឆេទៈ** ថ្ងៃសុក្រ ទី១២ ខែកុម្ភៈ ឆ្នាំ២០១០

**វេលាម៉ោង** ៖ ២:៣០ នាទីរសៀល

**ទីកន្លែង** ៖ ភោជនីយដ្ឋាន រ៉ាន់ ដែលមានអាសយដ្ឋាន ផ្ទះលេខ៥ ផ្លូវ១០២ (ក្បែរក្រសួងប្រៃសណីយ៍) ក្រុងភ្នំពេញ

**កម្មវត្ថុ** ៖ ការប្រកួតប្រជែងច្នៃម៉ូតពីសំណាក់កម្មករ-កម្មការិនីកាត់ដេរ ដែលមានឈ្មោះថា «ខ្ញុំមានតំលៃ» បានរកឃើញម្ចាស់ជ័យលាភីកាលពីចុងខែវិច្ឆិកា ឆ្នាំ២០០៩ កន្លងទៅនេះ។ គោលបំណងនៃយុទ្ធនាការនេះគឺដើម្បីផ្តល់ការទទួលស្គាល់ និងតំលៃដល់ឧស្សាហកម្មកាត់ដេរ និងដើម្បីលើកកម្ពស់ស្នាដៃរបស់កម្មករ-កម្មការិនីកាត់ដេរកម្ពុជា។ ក្រៅពីរង្វាន់ជាច្រើនដែលពួកគេបានទទួល អ្នកចូលរួមវគ្គផ្តាច់ព្រ័ត្រទាំង២០រូបបានទទួលការសិក្សាវគ្គបណ្តុះបណ្តាលធ្វើពុម្ពគំរូ ដូច្នេះពួកគេអាចបន្តក្តីសុបិនរបស់ពួកគេដែលចង់ក្លាយជាអ្នកច្នៃម៉ូត ដែលជាអាជីពដែលត្រូវការយ៉ាងខ្លាំងនៅក្នុងឧស្សាហកម្មនេះ។ ស្ត្រីវ័យក្មេងទាំងនេះបានចូលរៀនវគ្គបណ្តុះបណ្តាលនេះតាំងពីខែមករា ឆ្នាំ២០១០ ហើយឥឡូវនេះពួកគេបានបញ្ចប់ដោយជោគជ័យ។

នាថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០ខាងមុខនេះ ពិធីប្រគល់វិញ្ញាបនបត្រដល់បេក្ខជនផ្តាច់ព្រ័ត្រទាំងនេះ នឹងត្រូវធ្វើឡើងនៅភោជនីយដ្ឋាន រ៉ាន់ ក្នុងទីក្រុងភ្នំពេញ។ អ្នកពាក់ព័ន្ធនៅក្នុងឧស្សាហកម្មកាត់ដេរកម្ពុជា ក៏ដូចជាអ្នករៀបចំកម្មវិធីទាំងអស់នឹងជួបជុំជាមួយបេក្ខជនផ្តាច់ព្រ័ត្រទាំងអស់ដើម្បីអបអរសាទរដល់ពួកគេ និងដើម្បីប្រារព្ធពិធីបញ្ចប់នូវយុទ្ធនាការដ៏អស្ចារ្យនិងប្រកបដោយអត្ថន័យនេះ។

នេះគឺជាឱកាសមួយដ៏ល្អសម្រាប់សមាជិកអ្នកសារព័ត៌មានដើម្បីតាមដាន ពីការវិវឌ្ឍន៍នៃយុទ្ធនាការ «ខ្ញុំមានតំលៃ» នេះ និងដើម្បីជួបជាមួយកម្មករ-កម្មការិនីដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលនេះ និងអ្នកចូលរួមទាំងឡាយ។

**អ្នករៀបចំ ៖** អ្នករៀបចំនៃយុទ្ធនាការនេះមានដូចជា មជ្ឈមណ្ឌលអភិវឌ្ឍន៍ជំនាញកម្ពុជា (CASDEC)- មជ្ឈមណ្ឌលឧស្សាហកម្មដើម្បីបង្កើនលទ្ធភាពផលិតសំលៀកបំពាក់ (GIPC) សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) និង*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ (ILO-*BFC*) ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមក


លោក ប៊ុន យិញ (ខ្មែរ)
ទូរស័ព្ទ ៖ ០១២ ៩០២ ៩៩០
អ៊ីម៉ែល ៖ ying@ilo.org

កញ្ញា មីណា ម៉ាស្កូឡា (អង់គ្លេស)
ទូរស័ព្ទ ៖ ០៩២ ១២៧ ១១៧
អ៊ីម៉ែល ៖ maaskola@ilo.org